- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៧ /០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ .បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ .បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹតលេខ ២០ អនុក្រ.បក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋាន នាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ខែកញ្ញាឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និង នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញលិខិតលេខ ៧៦៣ សជណ.សរ ចុះថ្ងៃទី២៩ខែឧសភាឆ្នាំ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណី សំណើសុំការអនុញ្ញាតជាគោលការណ៍បង្កើតច្រកទ្វារព្រំដែនទ្វេភាគីកោះរកា ដែលមានភូមិសាស្ត្រស្ថិតនៅក្នុង ភូមិ កោះរកា ឃុំកោះរកា ស្រុកពាមជរ ខេត្ត ព្រៃវែង
- យោងប្រកាសលេខ ៣៨៩ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពមូលដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ ១:**

បង្កើត និងដាក់ឱ្យដំណើរការ ទីស្នាក់ការគយនិងរដ្ឋាករកោះរកា ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់សាខាគយនិងរដ្ឋាករខេត្តព្រៃវែង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានទីតាំងស្ថិតក្នុងភូមិសាស្ត្រ ភូមិកោះរកា ឃុំ កោះរកា ស្រុក ពាមជរ ខេត្ត ព្រៃវែង ។

**ប្រការ ២:**

ទីស្នាក់ការគយនិងរដ្ឋាករ កោះរកា ដឹកនាំដោយប្រធានម្នាក់មួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៣:**

ទីស្នាក់ការគយនិងរដ្ឋាករ កោះរកា មានភារកិច្ចដូចតទៅ ÷

១- គ្រប់គ្រងត្រួតពិនិត្យ និងប្រមូលពន្ធលើទំនិញនាំចេញនាំចូលគ្រប់ប្រភេទ នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែននេះ តាមបទប្បញ្ញត្តិជាធរមាន ។

២- ស្រាវជ្រាវទប់ស្កាត់និងបង្ក្រាបបទល្មើសគយគ្រប់ប្រភេទ ក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ខ្លួន តាមបទប្បញ្ញត្តិជាធរមាន ដោយសហការតាមការចាំបាច់ជាមួយអង្គភាពគយនិងរដ្ឋាករ ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានា ជាពិសេសអាជ្ញាធរមូលដ្ឋាន ។

៣- គ្រប់គ្រងត្រួតពិនិត្យ បែបបទគយលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ អ្នកដំណើរដែលចេញចូលព្រះរាជាណាចក្រកម្ពុជា ។

៤- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា ។

**ប្រការ ៤:**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- សាលាខេត្ត ព្រៃវែង

« ដើម្បីជូនជ្រាប »

- ដូចប្រការ ៤

« ដើម្បីអនុវត្ត »

- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៣១ សហវ.ប្រក

ភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ ២០១១

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការសម្របសម្រួល និង អង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្ត គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងបង្កើនផលិតភាពកសិកម្ម ក្រោមជំនួយឥតសំណងពីការសហប្រតិបត្តិការ...

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយប្រើប្រាស់នូវនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី
- បានឃើញប្រកាសលេខ ៩៧៥ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ

- បានឃើញប្រកាសលេខ ៦១៧ សហវ.ប្រក ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុមការងារសន្តិសុខស្បៀងថ្នាក់ជាតិសម្រាប់អនុវត្តគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ និងត្រូវបានបំពេញបន្ថែមដោយប្រកាសលេខ ៤៧៤ សហវ.ប្រក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីការប្រគល់ភារកិច្ចដល់ក្រុមការងារសន្តិសុខស្បៀងថ្នាក់ជាតិសម្រាប់អនុវត្តគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ ឱ្យទទួលបន្ទុកបន្ថែមសម្រាប់អនុវត្តប្រតិបត្តិការគោលនយោបាយអភិវឌ្ឍន៍កសិកម្មខ្នាតតូច និងការគាំពារសង្គម ។

## សម្រេច

**ប្រការ១:** បង្កើតគណៈកម្មការសម្របសម្រួល និង អង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងបង្កើនផលិតភាពកសិកម្មក្រោមថវិកាបង្វែរពីការសងមូលនិធិរូបិយវត្ថុអន្តរជាតិ ។

**ប្រការ២:** គណៈកម្មការសម្របសម្រួលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- **ឯកឧត្តម វង្សី វិស្សុត** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- នាយកគម្រោង និងអ្នកគ្រប់គ្រងទទួលបន្ទុកអនុវត្តសមាសភាគអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ | | សមាជិក |
| ៣- នាយកគម្រោង និងអ្នកគ្រប់គ្រងទទួលបន្ទុកអនុវត្តសមាសភាគបង្កើនផលិតភាពកសិកម្ម | | សមាជិក |
| ៤- **លោក ប៉ែន ធីរុង្គ** | អនុប្រធានទី១ នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | សមាជិក |
| ៥- **លោក រស់ បរម** | អនុប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | លេខាធិការ |

**ប្រការ៣:** គណៈកម្មការសម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងបង្កើនផលិតភាពកសិកម្ម មានភារកិច្ច ដូចខាងក្រោម:

១- ផ្តល់គោលការណ៍ណែនាំ និងគោលនយោបាយពាក់ព័ន្ធនឹងការអនុវត្តគម្រោង

២- តាមដានត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្តគម្រោង

៣- ដាក់ចេញគោលការណ៍អនុវត្ត និងវិធានការដោះស្រាយរាល់បញ្ហាប្រឈមទៅនឹងការអនុវត្តគម្រោង ។ ក្នុងករណីមានវេទយិតភាព ត្រូវស្នើសុំការណែនាំពីក្រុមការងារសន្តិសុខស្បៀងថ្នាក់ជាតិសម្រាប់អនុវត្តគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ និងអនុវត្តប្រត្តិបត្តិការគោលនយោបាយអភិវឌ្ឍន៍ កសិកម្មខ្នាតតូច និងគាំពារសង្គម

៤- រៀបចំរបាយការណ៍ស្តីពីការអនុវត្តគម្រោង ជូនក្រុមការងារសន្តិសុខស្បៀងថ្នាក់ជាតិសម្រាប់អនុវត្តគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ និងអនុវត្តប្រត្តិបត្តិការគោលនយោបាយអភិវឌ្ឍន៍កសិកម្មខ្នាតតូច និងគាំពារសង្គម

៥- សម្របសម្រួល និងផ្តល់ការគាំទ្រដល់ការអនុវត្តគម្រោង តាមការចាំបាច់ ។

**ប្រការ៤:** គណៈកម្មការសម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងបង្កើនផលិតភាពកសិកម្ម មានអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- **លោក ប៉ែនធីរុង្គ** | អនុប្រធានទី១ នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | នាយកគម្រោង |
| ២- **លោក តូច ច័ន្ទក្រឹស្នា** | ប្រធានការិយាល័យធនាគារពិភពលោក | អ្នកគ្រប់គ្រងគម្រោង |
| ៣- **លោក ហ៊ុល បុណ្ណារ័ត្ន** | អនុប្រធានការិយាល័យធនាគារពិភពលោក | ប្រធានផ្នែកទទួលបន្ទុកសមាសភាគអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ |

. ./.

| | | |
|---|---|---|
| ៤- **លោក យង់ ស៊ី** | អនុប្រធានការិយាល័យធនាគារពិភពលោក | ប្រធានផ្នែកទទួលបន្ទុកសមាសភាគបង្កើនផលិតភាពកសិកម្ម |
| ៥- **លោក ហុង ហឿន** | មន្ត្រីការិយាល័យធនាគារពិភពលោក | មន្ត្រីទទួលបន្ទុកសមាសភាគអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ |
| ៦- **លោក ឱម ម៉ាក់ធារិទ្ធ** | មន្ត្រីការិយាល័យធនាគារពិភពលោក | មន្ត្រីទទួលបន្ទុកសមាសភាគបង្កើនផលិតភាពកសិកម្ម |

**ប្រការ៥:** អង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងមានភារកិច្ចដូចខាងក្រោមៈ

១- ជាលេខាធិការរបស់គណៈកម្មការសម្របសម្រួលគម្រោង ក្នុងការសម្របសម្រួល និងតាមដានត្រួតពិនិត្យការអនុវត្តគម្រោង

២- គ្រប់គ្រង និងចាត់ចែងការងារហិរញ្ញវត្ថុគម្រោង

៣- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ការគ្រប់គ្រង និងអនុវត្តគម្រោង

៦- ស្នើឡើងនូវគោលការណ៍អនុវត្ត និងវិធានការដោះស្រាយរាល់បញ្ហាប្រឈមទៅនឹងការអនុវត្តគម្រោងជូនគណៈកម្មការសម្របសម្រួល

៧- បំពេញភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់គណៈកម្មការសម្របសម្រួល ។

**ប្រការ៦:** អគ្គលេខាធិការ អគ្គលេខាធិការរង គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**កន្លែងទទួលៈ**

- គ្រប់ថ្នាក់ដឹកនាំ នៃ កសហវ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ដូចប្រការ២ ប្រការ៤ និងប្រការ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ 002 សហវ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១១

# សេចក្ដីជូនដំណឹង
# អំពី
# ការប្រកាសផ្សព្វផ្សាយព័ត៌មានលទ្ធកម្មសាធារណៈ តាមរយៈគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមប្រកាសជូនដំណឹងដល់សាធារណជន ជាពិសេសអ្នកដេញថ្លៃទាំងអស់មេត្តាជ្រាបថា ដើម្បីបង្កើននូវភាពយុត្តិធម៌ តម្លាភាព ប្រសិទ្ធភាព ការសន្សំសំចៃខ្ពស់ក្នុងការដេញថ្លៃរាល់គម្រោងសាធារណៈ ស្របតាមកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការផ្សព្វផ្សាយព័ត៌មានលទ្ធកម្មសាធារណៈ ជាពិសេសការប្រកាសផ្សព្វផ្សាយសេចក្ដីជូនដំណឹងស្ដីពីការដេញថ្លៃជាសាធារណៈ តាមរយៈគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ www.mef.gov.kh/procurement បន្ថែមលើការផ្សព្វផ្សាយតាមរយៈសារព័ត៌មាន វិទ្យុ ទូរទស្សន៍ និងបណ្ដាញព័ត៌មាន ដែលបានធ្វើឡើងដោយស្ថាប័នអនុវត្តលទ្ធកម្មនាពេលកន្លងមក ។

សម្រាប់ជំហានដំបូង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការប្រកាសផ្សព្វផ្សាយតែអំពីការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក និងការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិប៉ុណ្ណោះ ។ រីឯការប្រកាសផ្សព្វផ្សាយអំពីការពិគ្រោះថ្លៃ ការស្ទង់តម្លៃ និងព័ត៌មានលទ្ធកម្មសាធារណៈផ្សេងៗទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងជូនដំណឹងនៅពេលក្រោយ ។

ការផ្សព្វផ្សាយព័ត៌មានលទ្ធកម្មសាធារណៈតាមរយៈគេហទំព័រ www.mef.gov.kh/procurement នេះនឹងត្រូវចាប់ផ្ដើមអនុវត្តចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ នេះតទៅ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបតាមការគួរ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ០៩៦...ឧរម.ភក.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០១...

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២១៦៧ /១០ គ.វ.ក ចុះថ្ងៃទី២៥.១០.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ថាយដិច ថេកណូឡូជី ចុះថ្ងៃទី១៨.១០.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ថាយដិច ថេកណូឡូជី តំណាងដោយ លោកស្រី PENG, MEI-CHIU សញ្ជាតិចិន (តៃវ៉ាន់) អាយុ៣៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 301525030 ចុះថ្ងៃទី១០.០៥.២០១០ មានអាសយដ្ឋានបច្ចុប្បន្នៈ 12F-3, No.190, fenghua Rd., Luzhu Township, Taoyuan Country, Taiwan ( R.O.C.) ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើនេះសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| សារធាតុគីមី សម្រាប់បោកគក់ ជ្រលក់ពណ៌ និងបោះពុម្ព ក្នុងវិស័យវាយនភ័ណ្ឌ | ៣៥២៩ |

-ផ្លាកឈ្មោះរោងចក្រ ៖ *"តាយដិច ថេកណូឡូជី (TAIDEX TECHNOLOGY CO.,LTD.)"*
-ទីតាំងរោងចក្រ ៖ *"ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបុព្វញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព នោះក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

ស៊ុយ សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ ...០៩៤ ឧរថ.កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញប្រកាសលេខ២១៥ ឧរថ.កឧ.ប្រក ចុះថ្ងៃទី១៨.០៣.២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
-បានឃើញលិខិតលេខ២២៩៧ /១០ គ.វ.ក ចុះថ្ងៃទី១១.១១.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ជី អិល ធី ខេមីខល ចុះថ្ងៃទី ០៣.១១.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ជី អិល ធី ខេមីខល តំណាងដោយ លោក KIM BYOUNG HOON សញ្ជាតិកូរ៉េ អាយុ៣៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ M65054518 ចុះថ្ងៃទី ០៩.១២.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ 231-40 CHEON HO-DONG, KANG DONG-KU, SEOUL, KOREA. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
| --- | --- |
| ១- ថង់ប្លាស្ទិក | ៣៥៦០ |
| ២- សន្លឹកប្លាស្ទិក | ៣៥៦០ |

-ផ្លាកឈ្មោះរោងចក្រ ៖ *"ជី អិល ធី ខេមីខល (G L T CHEMICAL CO., LTD.)"*

-ទីតាំងរោងចក្រ ៖ *"ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ចម្លងជូនៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ :

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ២៣៥៤ /១០ គ.វ.ក ចុះថ្ងៃទី១៧.១១.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន វ៉ាយ ឌី អិល ហ្វេកធើរី (ខេមបូឌា) ចុះថ្ងៃទី០៣.១១.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន វ៉ាយ ឌី អិល ហ្វេកធើរី (ខេមបូឌា) តំណាង ដោយ លោក YULONG ZHU សញ្ជាតិចិន អាយុ៥៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G17712452 ចុះថ្ងៃទី១៨.០៨.២០០៦ មានអាសយដ្ឋានបច្ចុប្បន្ន៖ Xi Kang Road, 699, No.3, Room 807, Shanghai, P.R. China ជាម្ចាស់រោងចក្រ ធ្វើការបង្កើត រោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev.4 Code |
|---|---|
| ស្លាកពាណិជ្ជសញ្ញា និងស្លាកសញ្ញាសំគាល់លើផលិតផល សម្លៀកបំពាក់ ស្បែកជើង និងមូក | ១៣៩៩ |


៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣

-ផ្លាកឈ្មោះរោងចក្រ ៖ " វ៉ាយ ឌី អិល ហ្វេកធើរី (ខេមបូឌា) (YDL FACTORY (CAMBODIA) CO., LTD.)"

-ទីតាំងរោងចក្រ ៖ "អាគារលេខ៨១ សួនឧស្សាហកម្មកាណាឌីយ៉ា ភូមិត្រពាំងថ្លឹង ផ្លូវចោមចៅ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ"

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១.** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២.** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនព្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ :

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២៤៣៦ /១០ គ.វ.ក ចុះថ្ងៃទី២៩.១១.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន យូនីហ្វម អេន សកស៍ អិម អេហ្វ ជី (ខេមបូឌា) ចុះថ្ងៃទី២៤.១១.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន យូនីហ្វម អេន សកស៍ អិម អេហ្វ ជី (ខេមបូឌា) តំណាងដោយ លោក ម៉ាក អេដវ៉ាត ហាតចុន ខាផែនធ័រ សញ្ជាតិខ្មែរ អាយុ៤៨ឆ្នាំ កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ ០១០៧១៧៩១៩ ចុះថ្ងៃទី០៣.០៨.២០០៩ មានអាសយដ្ឋានបច្ចុប្បន្នៈ ផ្ទះលេខ៣៨៣-៣៨៥អឺ៣ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះខណ្ឌដូនពេញ រាជធានីភ្នំពេញ ជាម្ចាស់រោងចក្រ ធ្វើការបង្កើត រោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ពេញ្ញាះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev 4 Code |
|---|---|
| ១-ស្រោមជើង | ១៤៣០ |
| ២-អាវថាក់ | ១៤៣០ |

-ផ្លាកឈ្មោះរោងចក្រ ៖ " *យូនីហ្វម អេន សុកស៍ អិម អេហ្វ ជី (ខេមបូឌា )*

*UNIFORM AND SOCKS MFG (CAMBODIA) CO., LTD.*"

-ទីតាំងរោងចក្រ ៖ " *ផ្លូវវេងស្រេង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ* "

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ស្តីពីការគ្រប់គ្រង រោងចក្រនិងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចដូល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរដោយទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបង្ហាញ សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោម តាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌ ទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យ បានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែល ប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ចម្លងជូនៈ**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៚៚✱៛៛៛

ស្ថាប័នប្រឆាំងអំពើពុករលួយ
អង្គភាពប្រឆាំងអំពើពុករលួយ
លេខ ០០៣/១១ ឥ.ស អ.ប.ព

# សេចក្ដីសម្រេច
# ស្ដីពី
# ទម្រង់បែបបទ និងនីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល

## ទេសរដ្ឋមន្ត្រី,ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្ដីពីការរៀបចំប្រព្រឹត្ត និងប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ ១.~** ទម្រង់បែបបទ និងនីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល

ត្រូវបានកំណត់ឱ្យប្រើប្រាស់ទម្រង់បែបបទ និងនីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល លើកដំបូង បន្ទាប់ពីច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយត្រូវបានប្រកាសឱ្យប្រើ រួមមាន៖

- ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រកាសទ្រព្យសម្បត្តិនិងបំណុល
- ទម្រង់បែបបទនៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល
- និងនីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល

**ប្រការ ២.~** ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រកាសទ្រព្យសម្បត្តិនិងបំណុល

អ្នកប្រកាសទ្រព្យសម្បត្តិនិងបំណុលត្រូវផ្ដល់ព័ត៌មានផ្ទាល់ខ្លួន (ដូចមានចែងក្នុងឧបសម្ព័ន្ធទី១) រួមមាន៖

- ព័ត៌មានអំពីអ្នកប្រកាស និងបិទរូបថត (ទំហំ៤គុណ៦)
- ព័ត៌មានអំពីស្វាមី ឬភរិយា និងកូន
- ឈ្មោះក្រសួងស្ថាប័នដែលអ្នកប្រកាសកំពុងធ្វើការ
- មូលហេតុប្រកាសទ្រព្យសម្បត្តិនិងបំណុល(លើកដំបូងនេះ សូមគូសយកប្រអប់ទី១☑តាមការ

កំណត់របស់អង្គភាពប្រឆាំងអំពើពុករលួយ)

**ប្រការ ៣.~ ទម្រង់នៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល**

ទម្រង់នៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល ចំពោះមុខនេះ(ដូចមានចែងក្នុងឧបសម្ព័ន្ធទី២) រួមមាន ៨ ចំណុចៈ

១- ការប្រកាសអំពីអចលនទ្រព្យ

២- ការប្រកាសអំពីយានយន្តនិងគ្រឿងចក្រ

៣- ការប្រកាសអំពីទ្រព្យសម្បត្តិដែលងាយដោះដូរជាសាច់ប្រាក់(មានតែ២មុខប៉ុណ្ណោះ គឺ គ្រឿងអលង្ការ និងនាឡិកា)

៤- ការប្រកាសអំពីសកម្មភាពអាជីវកម្ម ពាណិជ្ជកម្ម

៥- ការប្រកាសអំពីប្រាក់

៦- ការប្រកាសអំពីបំណុល

៧- ការប្រកាសអំពីចំណូល

៨- ការធានាអះអាង

- **ការប្រកាសអំពីទ្រព្យសម្បត្តិនិងបំណុល ពីលេខ១ដល់លេខ៥** មិនតម្រូវឱ្យប្រាប់ពីប្រភពហិរញ្ញប្បទាន សម្រាប់ការប្រកាសលើកដំបូង ក្នុងឆ្នាំ២០១១ នេះទេ ។ ការប្រកាសលើកទី២ មានរយៈពេល២ឆ្នាំក្រោយ ត្រូវបរិយាយឱ្យច្បាស់ពីប្រភពហិរញ្ញប្បទានតែលើទ្រព្យសម្បត្តិ ណាដែលបានកើនលើសពីការប្រកាសលើកដំបូងតែប៉ុណ្ណោះ ។
- **ការប្រកាសអំពីប្រាក់ (ចំណុចលេខ៥)** មិនមានការចាប់បង្ខំឱ្យប្រកាសពីចំនួនប្រាក់ក្នុងនិងក្រៅធនាគារដែលខ្លួនមាននោះទេ ។ សាមីខ្លួនចង់ប្រកាសក៏បាន មិនចង់ប្រកាសក៏បាន ។ ការមិនប្រកាសប្រាក់រក្សាទុកក្នុងធនាគារ មានតម្លៃស្មើនឹងការប្រកាសដែរ ព្រោះធនាគារជាកន្លែងរក្សាប្រាក់ស្របច្បាប់។ រីឯប្រាក់រក្សាទុកក្រៅធនាគារ ប្រសិនបើធ្វើការប្រកាស វាមានផលប្រយោជន៍យកមកធ្វើជាសំអាងស្របច្បាប់សម្រាប់បញ្ជាក់ពីចំណាយផ្សេងៗ នៅពេលដែលអង្គភាពប្រឆាំងអំពើពុករលួយសាកសួរ ។ ហេតុនេះ ប្រាក់នៅក្រៅពីធនាគារដែលមិនបាន ប្រកាសមិនអាចយកមកធ្វើជាសំអាងសម្រាប់បញ្ជាក់ការធ្វើអំណោយ ការទិញអចលនវត្ថុ ចលនវត្ថុ ការទិញ ឬដាក់ទុនធ្វើអ្វីទៀត ដែលនាំឱ្យមានកំណើនប្រាក់ និងកំណើនទ្រព្យសម្បត្តិរបស់សាមីខ្លួនបានទេ ។ ប្រាក់សំដៅដល់ប្រាក់រៀល រូបិយប័ណ្ណបរទេស មាសដុំ មាសគីឡូ របស់របរផ្សេងទៀត ដែលមិនមែនជាអលង្ការ ហើយប្រើប្រាស់សម្រាប់ការលក់ ដោះដូរ និងចាយវាយ ។

**ប្រការ ៤.~ នីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល ផ្នែក ក**

ក) អ្នកប្រកាសម្នាក់ៗ ត្រូវដាក់ជូនដោយផ្ទាល់មកអង្គភាពប្រឆាំងអំពើពុករលួយនូវឯកសារប្រកាសទ្រព្យសម្បត្តិនិងបំណុលរបស់ខ្លួន មានន័យថា ទោះបីសាមីខ្លួនពឹងពាក់អ្នកណាម្នាក់ឱ្យជួយសរសេរ ឬវាយកុំព្យូទ័រ ឬកាន់យកឯកសារប្រកាសទ្រព្យសម្បត្តិនេះមកជូនអង្គភាពប្រឆាំងអំពើពុករលួយក៏ដោយ ក៏សាមីខ្លួនត្រូវផ្តិតមេដៃរបស់ខ្លួនដោយផ្ទាល់ (គ្មានអ្នកផ្សេងផ្តិតមេដៃជំនួសបានទេ) ហើយទទួលស្គាល់ថា ខ្លឹមសារនិងស្នាមមេដៃលើឯកសារប្រកាសទ្រព្យសម្បត្តិនិងបំណុល ពិតជារបស់ខ្លួនមែន ។

ខ) ពេលឯកសារប្រកាសទ្រព្យសម្បត្តិនិងបំណុលនេះ បញ្ជូនមកដល់អង្គភាពប្រឆាំងអំពើពុករលួយដោយសាមីខ្លួនក្តី ឬតាមរយៈក្រុមជនបង្គោលប្រឆាំងអំពើពុករលួយប្រចាំក្រសួង ស្ថាប័ន ឬអ្នកណាដែលខ្លួនទុកចិត្តផ្ញើមកឱ្យក្តី ឬតាមរយៈប្រៃសណីយ៍ក្តី អង្គភាពប្រឆាំងអំពើពុករលួយ

ប្រថាប់ត្រានិងចុះហត្ថលេខាលើមាត់ស្រោមសំបុត្រ និងប្រគល់ឬផ្ញើទៅវិញតាមរក្រុកបញ្ជូនមក នោះ ចំនួនមួយច្បាប់ ដើម្បីសាមីខ្លួនទុកជាឯកសារ ។

**ប្រការ ៥**.~ នីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល ផ្នែក ខ

១- បុគ្គលប្រកាសទ្រព្យសម្បត្តិនិងបំណុល ដែលមានតួនាទីច្រើនកន្លែងត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុលតែមួយកន្លែង គឺនៅក្រសួងឬស្ថាប័នណាមួយដែលតួនាទីរបស់ខ្លួនខ្ពស់ជាងគេ ឬតាមការកំណត់របស់អង្គភាពប្រឆាំងអំពើពុករលួយ ដូចមានចែងក្នុងចំណុចណាមួយនៃប្រការ ៥ នេះ ។

២- ឧកញ៉ា ជាងារមួយ ហេតុនេះមិនមានការចាំបាច់ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុលទេ ។ ដោយឡែក បើឧកញ៉ានោះ ឬបុគ្គលណាម្នាក់ជាមន្ត្រីសាធារណៈដែលមានអាណត្តិជ្រើសតាំង (សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ខណ្ឌ ស្រុក សង្កាត់ ឃុំ...) ឬជាមន្ត្រីរាជការស៊ីវិល (មានក្របខ័ណ្ឌក្តី គ្មានក្របខ័ណ្ឌក្តី) មន្ត្រីយោធា នគរបាលជាតិ ឬអ្នករាជការសាធារណៈផ្សេងទៀតដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល ។

៣- មន្ត្រីរាជការស៊ីវិល (មានក្របខ័ណ្ឌក្តី គ្មានក្របខ័ណ្ឌក្តី) មន្ត្រីយោធា នគរបាលជាតិនិងអ្នករាជការសាធារណៈដែលមានមុខងារបន្ថែម ឬឋានន្តរស័ក្តិតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យនោះ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលផងដែរ ។ ឧទាហរណ៍ អនុប្រធានការិយាល័យមួយរូប ហើយក៏ជាទីប្រឹក្សាថ្នាក់ដឹកនាំដែលតែងតាំងដោយព្រះរាជក្រឹត្យ ក៏ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុលដែរ ។ អនុប្រធាននាយកដ្ឋាននគរបាលជាតិ ឬអនុប្រធាននាយកដ្ឋាននៅក្រសួងការពារជាតិតែងតាំងដោយប្រកាស តែឋានន្តរស័ក្តិរបស់អ្នកទាំងនោះ (វរៈសេនីយ៍ឯក ឬឧត្តមសេនីយ៍) ដែលតែងតាំងដោយអនុក្រឹត្យ ឬព្រះរាជក្រឹត្យ ក៏ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុលដែរ ។

៤- ប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភា សមាជិករដ្ឋសភា និងមន្ត្រីក្នុងអគ្គលេខាធិការដ្ឋាននៃរដ្ឋសភាចាប់ពីប្រធាននាយកដ្ឋានឡើងទៅ ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល ជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។ សមាជិករដ្ឋសភាណាដែលជាសមាជិករាជរដ្ឋាភិបាល ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល នៅជាមួយផ្នែករាជរដ្ឋាភិបាលវិញ។

៥- ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភា សមាជិកព្រឹទ្ធសភា និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភាចាប់ពីប្រធាននាយកដ្ឋានឡើងទៅ ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល ជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយនៃអគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភា ។

៦- នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលដែលមិនមែនជាប្រធានក្រសួងស្ថាប័នណាមួយ ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុលជាមួយអង្គភាពប្រឆាំងអំពើពុករលួយ។ សមាជិករាជរដ្ឋាភិបាលដទៃទៀត ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល តាមសាមីក្រសួង ស្ថាប័ន ។

៧- សមាជិករាជរដ្ឋាភិបាល និងមន្ត្រីមកពីក្រសួង ស្ថាប័នផ្សេងទៀតដែលជាប្រធាន អនុប្រធានសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងជាប្រធាន អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល ជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ។

៨- ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ខណ្ឌ ស្រុក សង្កាត់ ឃុំ និងមន្ត្រីនគរបាលជាតិ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយនៃក្រសួងមហាផ្ទៃ ។

៩- មន្ត្រីយោធានិងមន្ត្រីស៊ីវិលបម្រើការងារយោធា ដែលមានឋានន្តរស័ក្តិនិងការតែងតាំងដោយ

អនុក្រឹត្យ ឬព្រះរាជក្រឹត្យ ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល ជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយនៃក្រសួងការពារជាតិ ។

១០-ចៅក្រមអាសនៈ ចៅក្រមអយ្យការ សារការី ក្រឡាបញ្ជី និងអាជ្ញាសាលា ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល ជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយនៃក្រសួងយុត្តិធម៌ ។

១១-ក្រុមប្រឹក្សាធម្មនុញ្ញ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើងទៅ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើងទៅ ថ្នាក់ដឹកនាំ និងមន្ត្រីចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើងទៅនៃធនាគារជាតិកម្ពុជា និងអាជ្ញាធរសវនកម្មជាតិ ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល ជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយនៃសាមីស្ថាប័ននីមួយៗ។

១២-ការប្រកាសទ្រព្យសម្បត្តិនិងបំណុលរបស់មន្ត្រីដែលតែងតាំងដោយប្រកាស និងថ្នាក់ដឹកនាំសង្គមស៊ីវិល នឹងត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែក ។

**ប្រការ ៦.~ នីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល ផ្នែក គ**

ត្រូវបង្កើតក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ពីមួយក្រុមឡើងទៅ នៅក្នុងក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈនីមួយៗ ដើម្បីចូលរួមអប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើពុករលួយ ដោយប្រកាស ឬសេចក្តីសម្រេចរបស់ប្រធានសាមីក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ ។

ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ អាចមានសមាជិកពី៣(បី)រូប ដល់១១(ដប់មួយ)រូប ក្នុងមួយក្រុមៗ ក្នុងនោះមានប្រធានក្រុម១(មួយ)រូប អនុប្រធានក្រុម១(មួយ)ទៅ២(ពីរ)រូប ។

សមាជិកនៃក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

-ជាមន្ត្រីនៅក្នុងក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ ហើយមានតួនាទីដែលអាចដឹកនាំ និងបំពេញការងារក្រុមជនបង្គោលបាន

-មានភាពស្អាតស្អំ ឈ្លាសវៃ សមត្ថភាព ឆន្ទៈ និងពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញការងារប្រឆាំងអំពើពុករលួយ។

ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ទទួលបន្ទុករាល់ការងារពាក់ព័ន្ធនឹងការប្រកាសទ្រព្យសម្បត្តិនិងបំណុល ដូចជា៖

- ធ្វើបញ្ជីឈ្មោះអ្នកត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុលក្នុងក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ រួចបញ្ជូនមកអង្គភាពប្រឆាំងអំពើពុករលួយ យូរបំផុតនៅត្រឹមថ្ងៃទី០៧ ខែមករា ឆ្នាំ២០១១
- ផ្សព្វផ្សាយគោលការណ៍ណែនាំអំពីការប្រកាសទ្រព្យសម្បត្តិនិងបំណុល
- រៀបចំបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិនិងបំណុលទាំងអស់ មកអង្គភាពប្រឆាំងអំពើពុករលួយ និងពាំនាំយកឯកសារប្រកាសទ្រព្យសម្បត្តិនិងបំណុលមួយច្បាប់ ទៅសាមីអ្នកប្រកាសទ្រព្យសម្បត្តិនិងបំណុលវិញ បន្ទាប់ពីអង្គភាពប្រឆាំងអំពើពុករលួយបានពិនិត្យ និងប្រថាប់ត្រាទទួលរួចមក តាមប្រតិទិនដែលចែងក្នុងសេចក្តីប្រកាសនេះ ។

តួនាទីនិងភារកិច្ចផ្សេងទៀតរបស់ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ មានចែងក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ ។

**ប្រការ ៧.~ នីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល ផ្នែក ឃ**

ចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ អ្នកត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល ត្រូវចាប់ផ្តើមផ្ញើមកអង្គភាពប្រឆាំងអំពើពុករលួយនូវឯកសារប្រកាសទ្រព្យសម្បត្តិនិងបំណុលរបស់ខ្លួន ចំនួនពីរច្បាប់ (ឧបសម្ព័ន្ធទី២) អមដោយព័ត៌មានផ្ទាល់ខ្លួន(ឧបសម្ព័ន្ធទី១) ដោយមកផ្ទាល់ក្តី ឬផ្ញើតាមអ្នកដែលខ្លួនទុកចិត្តក្តី ឬតាមរយៈក្រុមជនបង្គោលប្រឆាំងអំពើពុករលួយនៃក្រសួងស្ថាប័នអង្គភាពសាធារណៈក្តី ឬតាមរយៈប្រៃសណីយ៍ក្តី ។

ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយនៃក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈនីមួយៗ ត្រូវផ្ញើបញ្ជីឈ្មោះអ្នកត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល មកអង្គភាពប្រឆាំងអំពើពុករលួយ ។

**ប្រការ ៨.~ នីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិនិងបំណុល ផ្នែក ង**

ក) អង្គភាពប្រឆាំងអំពើពុករលួយ (នាយកដ្ឋានប្រកាសទ្រព្យសម្បត្តិ និងបំណុល) ទទួលនូវឯកសារប្រកាសទ្រព្យសម្បត្តិនិងបំណុល៖

- ចាប់ពីសប្តាហ៍ទី៣នៃខែមករា ឆ្នាំ២០១១ ពី៖
    - ក្រសួងធម្មការ និងសាសនា
    - ក្រសួងកិច្ចការនារី
    - ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
    - ក្រសួងទេសចរណ៍
    - រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
    - រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ចាប់ពីសប្តាហ៍ទី៤នៃខែមករា ឆ្នាំ២០១១ ពី៖
    - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
    - ក្រសួងធនធានទឹក និងឧត្តុនិយម
    - ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
    - ក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍
    - ក្រសួងសុខាភិបាល
    - ក្រសួងបរិស្ថាន
- ចាប់ពីសប្តាហ៍ទី១នៃខែកុម្ភៈ ឆ្នាំ២០១១ ពី៖
    - ក្រសួងសាធារណការ និងដឹកជញ្ជូន
    - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
    - ក្រសួងព័ត៌មាន
    - ក្រសួងយុត្តិធម៌ (និងចៅក្រមអាសនៈ ចៅក្រមអយ្យការ សារការី ក្រឡាបញ្ជី និងអាជ្ញាសាលា)
    - ក្រសួងផែនការ
    - ក្រសួងអប់រំ យុវជន និងកីឡា
- ចាប់ពីសប្តាហ៍ទី២នៃខែកុម្ភៈ ឆ្នាំ២០១១ ពី៖
    - ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
    - ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា

- ចាប់ពីសប្តាហ៍ទី៣នៃខែកុម្ភៈ ឆ្នាំ២០១១ ពីៈ
  - ក្រសួងពាណិជ្ជកម្ម
  - ក្រសួងមហាផ្ទៃ (និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ខណ្ឌ ស្រុក សង្កាត់ ឃុំ និងនគរបាលជាតិ)
  - ក្រុមប្រឹក្សាធម្មនុញ្ញ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ
  - គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
  - ធនាគារជាតិនៃកម្ពុជា
  - អាជ្ញាធរសវនកម្មជាតិ

- ចាប់ពីសប្តាហ៍ទី៤នៃខែកុម្ភៈ ឆ្នាំ២០១១ ពីៈ
  - ទីស្តីការគណៈរដ្ឋមន្ត្រី
  - ក្រសួងការពារជាតិ (និងមន្ត្រីយោធា និងមន្ត្រីស៊ីវិលបម្រើការងារយោធាដែលមានឋានន្តរស័ក្តិនិងការតែងតាំងដោយអនុក្រឹត្យ ឬព្រះរាជក្រឹត្យ)
  - រដ្ឋសភា និងអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា
  - ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភា

- ចាប់ពីសប្តាហ៍ទី១នៃខែមីនា ឆ្នាំ២០១១ ពីៈ
  - សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលដទៃទៀតដែលមិនមែនជាប្រធានក្រសួង ស្ថាប័នណាមួយ (អង្គភាពប្រឆាំងអំពើពុករលួយនឹងទំនាក់ទំនងផ្ទាល់)
  - ស្ថាប័នប្រឆាំងអំពើពុករលួយ
  - ក្រសួងព្រះបរមរាជវាំង

ខ) អាជ្ញាធរ គណៈកម្មការ គណៈកម្មាធិការ ក្រុមប្រឹក្សាជាតិ រាជបណ្ឌិតសភា សាលា (ដូចជាសាលាភូមិន្ទរដ្ឋបាលជាដើម) អង្គភាពសាធារណៈផ្សេងទៀតដែលបង្កើតដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែកពីក្រសួង ស្ថាប័ន ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល នៅជាមួយក្រសួង ស្ថាប័នដែលខ្លួនចំណុះ។

**ប្រការ ៩.~** កាលបរិច្ឆេទចុងក្រោយឈប់ទទួលឯកសារប្រកាសទ្រព្យសម្បត្តិនិងបំណុលលើកដំបូង

ចំពោះមុខ ត្រូវបានកំណត់កាលបរិច្ឆេទចុងក្រោយឈប់ទទួលឯកសារប្រកាសទ្រព្យសម្បត្តិនិងបំណុលលើកដំបូងនេះ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១ ។ អង្គភាពប្រឆាំងអំពើពុករលួយ ធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈ តាមបណ្តាញសារព័ត៌មាន ដើម្បីឱ្យអ្នកប្រកាសទ្រព្យសម្បត្តិនិងបំណុល ដែលមិនទាន់បានបញ្ជូននូវឯកសារប្រកាសទ្រព្យសម្បត្តិនិងបំណុល មកដល់អង្គភាពប្រឆាំងអំពើពុករលួយដោយខានមិនបានជាកំហិត ។ ផុតពីកាលបរិច្ឆេទនេះ អង្គភាពប្រឆាំងអំពើពុករលួយ ចាត់ទុកថាអ្នកដែល

ត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុលនោះ មិនបានប្រកាសទ្រព្យសម្បត្តិនិងបំណុលរបស់ខ្លួនទេ ។

**ប្រការ ១០.~** អាសយដ្ឋានអង្គភាពប្រឆាំងអំពើពុករលួយ

អង្គភាពប្រឆាំងអំពើពុករលួយ មានអាសយដ្ឋានលេខ៥៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ មន្ត្រី និងលេខទូរស័ព្ទទំនាក់ទំនង៖

-លោក ណុប សាម៉េត (០១២ ៨៩៨ ៩១៣)

-លោក ទូច ស៊ុនណារី (០១២ ៦៥៦ ៩៩៨ )

-លោក ឯវ ភិរម្យ (០១២ ៣១០ ៨៣១)

-កញ្ញា ឃុន រចនា (០១២ ៧៨២ ៥៦១)

-និងអ្នកស្រី អ៊ូ ស៊ីថា (០១៦ ៨៥១ ៥៨៦)។

**ប្រការ ១១.~** សុពលភាពអនុវត្ត

សេចក្តីសម្រេចនេះ មានសុពលភាពអនុវត្ត ចាប់តាំងពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១

ទេសរដ្ឋមន្ត្រី, ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

**ឱម យ៉ិនទៀង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. 0៤៤ MOC / SM 2011

# ប្រកាស
## ស្តីពី
## ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០២៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ .បក ចុះថ្ងៃទី ១២ កក្កដា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

-បានឃើញប្រកាសលេខ ២១១ MOC/SM ២០០៧ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា របស់ក្រសួងពាណិជ្ជកម្ម

-បានឃើញប្រកាសលេខ ១០៥ MOC/SM ២០០៩ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពី អំពីនីតិវិធីណែនាំការចុះបញ្ជី និងការការពារម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ

-យោងតាមសំណូមពរចាំបាច់នៃការងារ

## ស ម្រេ ច

### ប្រការ ១ : គោលដៅ

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវ និងនីតិវិធីទទួលស្គាល់បុគ្គលធ្វើជាតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។

## ប្រការ ២ : គោលបំណង

ប្រកាសនេះមានគោលបំណង :

១- គ្រប់គ្រង និងពង្រឹងសមត្ថភាពរបស់តំណាងស្របច្បាប់នៃម្ចាស់ម៉ាក់ ដើម្បីសម្រួលដល់ការងារចុះបញ្ជី និង កិច្ចការដទៃទៀតដែលទាក់ទងនឹងម៉ាក និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឱ្យមានភាពរលូនប្រកបដោយប្រសិទ្ធភាព។

២- ផ្តល់ភាពងាយស្រួលដល់ម្ចាស់ម៉ាកក្នុងការធ្វើអាជីវកម្ម និង ការការពារសិទ្ធិរបស់ខ្លួន តាមរយៈតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

## ប្រការ ៣ : និយមន័យ និង វិសាលភាព

ម៉ាកសំដៅដល់ ម៉ាក និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ប្រកាសនេះគ្រប់ដណ្តប់ទៅលើការងារផ្សេងៗដែលទាក់ទងទៅនឹងម៉ាក ដូចជា ការចុះបញ្ជី ការធ្វើអាជីវកម្ម ការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញា និងការអនុវត្តន៍សិទ្ធិរបស់ម្ចាស់ម៉ាកក្នុង និង ក្រៅប្រទេស ជាដើម។

## ប្រការ ៤ : ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក

១- ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក គឺជារូបវន្តបុគ្គល ឬនីតិបុគ្គល តំណាងឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ដើម្បីបំពេញកិច្ចការចំពោះមុខនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។ ភ្នាក់ងារតំណាងស្របច្បាប់ នៃម្ចាស់ម៉ាក ត្រូវមានលក្ខណៈសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ហើយត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការក្នុងបញ្ជីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួង ពាណិជ្ជកម្ម។

២- បរិមាណភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក មិនត្រូវបានកំណត់ចំនួនឡើយ។ រូបវន្តបុគ្គលដែលបានប្រឡងជាប់ជាស្ថាពរ ត្រូវបានចាត់ទុកថាមានគុណសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ក្នុងការធ្វើជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

៣- ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក អាចបង្ហាញខ្លួនក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជា តែក្នុងករណី មិនផ្ទុយនឹងច្បាប់ និង បទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា។

៤- ផ្អែកតាមសំណើ រូបវន្តបុគ្គលណាមួយអាចនឹងត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្នុងបញ្ជីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក លុះត្រាតែបុគ្គលនោះ បំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម :

-មានសញ្ជាតិខ្មែរ និង

-មានទីលំនៅអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង

-មានទីតាំងប្រកបអាជីវកម្ម ឬការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង

-ជាប់ជាស្ថាពរក្នុងការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឬត្រូវបានចាត់ទុកថា មានគុណសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ដូចមានចែងក្នុងប្រការ ២៦ និង

-មិនផ្ទុយនឹងច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

៥- ផ្អែកតាមសំណើ នីតិបុគ្គលអាចនឹងត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្នុងបញ្ជីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក លុះត្រាតែ ÷

-មានបុគ្គលិកជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកយ៉ាងតិចមួយនាក់ឈរឈ្មោះអោយ និង

-មានទីលំនៅអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦-រូបវន្តបុគ្គលជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកម្នាក់ អាចឈរឈ្មោះអោយនីតិបុគ្គលជាភ្នាក់ងារតំណាងស្របច្បាប់តែមួយគត់។

## ប្រការ ៥ : ការរៀបចំការប្រឡង

ក្នុងករណីមានចំនួនបេក្ខជនសមស្រប ការប្រឡងសមត្ថភាពសម្រាប់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក នឹងត្រូវរៀបចំធ្វើឡើង យ៉ាងតិចមួយដងក្នុងមួយឆ្នាំ ឬតាមការចាំបាច់។ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នឹងរៀបចំបង្កើតក្រុមប្រឹក្សាប្រឡង គណៈកម្មការប្រឡង និង លេខាធិការដ្ឋានប្រឡង។

## ប្រការ ៦ : ក្រុមប្រឹក្សាប្រឡង

១- ក្រុមប្រឹក្សាប្រឡងមានតួនាទីជ្រើសរើសមន្ត្រីជំនាញ ដើម្បីបង្រៀនដល់បេក្ខជនត្រៀមប្រឡង និងរៀបចំការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

២- ក្រុមប្រឹក្សាប្រឡង មានសមាសភាពចំនួន ០៧ រូប រួមមាន ÷

ក-ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម

ខ-ប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងពាណិជ្ជកម្ម

គ-មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ចំនួន ០៣រូប និងមន្ត្រីនាយកដ្ឋានបុគ្គលិក នៃក្រសួងពាណិជ្ជកម្ម ចំនួន ០២រូប ដែលស្នើសុំតែងតាំងដោយប្រធាននាយកដ្ឋានសាមី។

៣- ប្រធាន និងអនុប្រធានក្រុមប្រឹក្សាប្រឡង ត្រូវជ្រើសរើសចេញពីសមាជិករបស់ខ្លួន។

៤-ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា និងប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងពាណិជ្ជកម្ម អាចតែងតាំងមន្ត្រីមួយរូបតាមជម្រើសរបស់ខ្លួន ដើម្បីកាន់តំណែងជំនួសក្នុងក្រុមប្រឹក្សាប្រឡង សម្រាប់រយៈពេលណាមួយ។

## ប្រការ ៧ : សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រឡង

១- រៀបចំសមាសភាពគណៈកម្មការប្រឡង និង លេខាធិការដ្ឋានប្រឡង ដើម្បីសុំការឯកភាពពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

២- ជ្រើសរើសគ្រូបង្រៀនជំនាញកម្មសិទ្ធិបញ្ញាក្នុងចំណោមមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលមានសមត្ថភាព និងគុណសម្បត្តិ ដើម្បីបង្រៀនដល់បេក្ខជនត្រៀមប្រឡង។

៣- ក្រុមប្រឹក្សាត្រូវផ្តល់ការណែនាំដែលចាំបាច់ទៅគណៈកម្មការប្រឡង សម្រាប់ការរៀបចំវិញ្ញាសាប្រឡង ពិនិត្យមើលសេចក្តីព្រាង និងធ្វើការជ្រើសរើសអត្ថបទចុងក្រោយ សម្រាប់វិញ្ញាសាប្រឡង។

៤- ក្រុមប្រឹក្សាត្រូវសម្រេច ជាពិសេស ទៅលើបញ្ជីសៀវភៅ និងឯកសារ ដែលបេក្ខជនអាចប្រើប្រាស់ក្នុងពេលប្រឡង និងណែនាំលេខាធិការដ្ឋានប្រឡង អំពីវិធានការដែលត្រូវធ្វើចំពោះបេក្ខជន ដែលបានរកឃើញថា កំពុង ឬ មានបំណងលួចចម្លង។

៥- ក្រុមប្រឹក្សាត្រូវកំណត់ពិន្ទុសម្រាប់វិញ្ញាសានីមួយៗ ត្រួតពិនិត្យពិន្ទុ ដែលផ្តល់ដោយគណៈកម្មការប្រឡង ហើយសម្រេចបឋមថា បេក្ខជនមួយណាបានប្រឡងជាប់ ឬ ធ្លាក់។ សមាជិកណាមួយរបស់ក្រុមប្រឹក្សា ដែលបានធ្វើជាសមាជិករបស់គណៈកម្មការប្រឡង ហើយបានឱ្យពិន្ទុបេក្ខជនប្រឡង មិនអាចចូលរួមក្នុងការសម្រេចចិត្តនេះបានទេ។

## ប្រការ ៨ : កិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រឡង

ក្រុមប្រឹក្សា ត្រូវកោះប្រជុំដោយប្រធានរបស់ខ្លួន។ កូរ៉ុមនៃកិច្ចប្រជុំ ដែលមានសមាជិកចំនួន ០៤(បួន) រូប អាចដំណើការកិច្ចប្រជុំបាន។ សេចក្តីសម្រេចបឋមរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ សេចក្តីសម្រេចរបស់អង្គប្រជុំត្រូវយកតាមសម្លេង ៥០ ភាគរយ បូក ១ របស់សមាជិកចូលរួម ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាព។

ប្រធានក្រុមប្រឹក្សាប្រឡង ត្រូវរាយការណ៍សុំសេចក្តីសម្រេចចុងក្រោយពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អំពីសមាសភាពបេក្ខជនដែលប្រឡងជាប់ជាស្ថាពរ។

## ប្រការ ៩ : អាណត្តិរបស់ក្រុមប្រឹក្សាប្រឡង

សមាជិកក្រុមប្រឹក្សាប្រឡងដែលបានតែងតាំង នឹងកាន់មុខតំណែងមានរយៈពេល ០៣ (បី) ឆ្នាំ។ នៅពេលផុតរយៈពេលនេះ សមាជិកក្រុមប្រឹក្សាអាចត្រូវបានតែងតាំងសាជាថ្មី។

## ប្រការ ១០ : គណៈកម្មការប្រឡង

១- ក្នុងការរៀបចំប្រឡង ក្រសួងពាណិជ្ជកម្មត្រូវតែងតាំងគណៈកម្មការប្រឡងមួយ ឬច្រើន តាមការស្នើសុំរបស់ក្រុមប្រឹក្សាប្រឡង

២- គណៈកម្មការនីមួយៗ ត្រូវបង្កើតឡើងដោយមានការចូលរួមពីមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា និង មន្ត្រីនាយកដ្ឋានបុគ្គលិកនៃក្រសួងពាណិជ្ជកម្ម

៣- សមាជិកច្រើនបំផុត ០៣ (បី) រូប របស់ក្រុមប្រឹក្សាប្រឡង អាចត្រូវបានតែងតាំងជាសមាជិករបស់គណៈកម្មការ។

## ប្រការ ១១ : ភារកិច្ចរបស់គណៈកម្មការប្រឡង

គណៈកម្មការប្រឡង មានភារកិច្ចទទួលខុសត្រូវ ÷

១- រៀបចំវិញ្ញាសាប្រឡង ដោយអនុលោមទៅតាមការណែនាំរបស់ក្រុមប្រឹក្សា និង បញ្ជាក់ពីសារៈសំខាន់ពាក់ព័ន្ធរបស់សំណួរនីមួយៗ នៅពេលដែលចាំបាច់

២- ផ្តល់ចម្លើយនៃវិញ្ញាសាប្រឡង ជាមួយនឹងតារាងកំណត់ពិន្ទុ

៣- ប្រគល់ចម្លើយនិងពិន្ទុរបស់បេក្ខជនទៅអោយក្រុមប្រឹក្សា

៤- កិច្ចការផ្សេងៗទៀត ដែលប្រគល់ជូនដោយក្រុមប្រឹក្សា។

## ប្រការ ១២ : លេខាធិការដ្ឋានប្រឡង

ក្រសួងពាណិជ្ជកម្ម នឹងផ្តល់ទីកន្លែង សម្ភាររដ្ឋបាលចាំបាច់ដែលបានមកពីការបង់ប្រាក់ឧបត្ថម្ភក្នុងការប្រឡង ទៅឱ្យក្រុមប្រឹក្សា និង គណៈកម្មការប្រឡង សម្រាប់បង្កើតលេខាធិការដ្ឋានប្រឡង។

**ប្រការ ១៣ : ភារកិច្ចរបស់លេខាធិការដ្ឋាន**

១- លេខាធិការដ្ឋានត្រូវ:

- ជួយការងារក្រុមប្រឹក្សា និងគណៈកម្មការប្រឡង
- ផ្សព្វផ្សាយពត៌មាន អំពីវគ្គបណ្តុះបណ្តាលត្រៀមប្រឡង
- ទទួលពាក្យសុំចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលត្រៀមប្រឡង និង ប្រឡង
- ត្រៀមមធ្យោបាយក្នុងការបង្រៀន និង ប្រឡង
- ចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យការប្រឡង
- បំពេញការងារផ្សេងៗតាមការណែនាំរបស់ក្រុមប្រឹក្សានិងគណៈកម្មការប្រឡង ។

២- លេខាធិការដ្ឋាន ត្រូវទទួលខុសត្រូវចំពោះការបោះពុម្ពផ្សាយព័ត៌មានទាំងអស់ដែលបេក្ខជនត្រូវការ រួមមាន កាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះឈ្មោះ និងឯកសារដែលចាំបាច់នានា សម្រាប់ការដាក់ពាក្យ

៣- អនុលោមទៅតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សា លេខាធិការដ្ឋានប្រឡងនឹងសម្រេច អំពីការចុះឈ្មោះបេក្ខជន។ លេខាធិការដ្ឋានត្រូវរៀបចំធ្វើការប្រឡង ហើយចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យការប្រឡង ។

**ប្រការ ១៤ : សេចក្តីជូនដំណឹងអំពីការប្រឡងជ្រើសរើស**

សេចក្តីជូនដំណឹងអំពីការប្រឡងជ្រើសរើស ត្រូវផ្សព្វផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ និង ឬ បណ្តាញសារព័ត៌មាន ដែលបញ្ជាក់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះឈ្មោះ និង កាលបរិច្ឆេទនៃការប្រឡង និងឯកសារ ដែលតម្រូវ ។

**ប្រការ ១៥ : ពាក្យសុំចុះឈ្មោះប្រឡង**

១- ពាក្យសុំចុះឈ្មោះប្រឡង ត្រូវដាក់នៅលេខាធិការដ្ឋានប្រឡង

២- ពាក្យសុំចុះឈ្មោះត្រូវបញ្ជាក់ពី គោត្តនាម នាមខ្លួន អាសយដ្ឋាន និង សញ្ជាតិ របស់បេក្ខជន និងត្រូវ ភ្ជាប់មកជាមួយនូវ ÷

ក- ភស្តុតាងបញ្ជាក់ពីលក្ខណៈសម្បត្តិ ដូចមានចែងក្នុងប្រការ ២១

ខ- លិខិតបញ្ជាក់ថា បានបញ្ចប់វគ្គបណ្តុះបណ្តាលត្រៀមដោយជោគជ័យ ដែលរៀបចំដោយ ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ១៦ : ការចុះឈ្មោះ និងសេចក្តីជូនដំណឹង**

១- លេខាធិការដ្ឋានប្រឡងត្រូវជូនដំណឹងដល់បេក្ខជន អំពីការទទួលយក ឬការបដិសេធពាក្យសុំចុះឈ្មោះ របស់បេក្ខជន ។ ក្នុងករណីពាក្យស្នើសុំត្រូវបានបដិសេធ ត្រូវបញ្ជាក់ពីមូលហេតុ។

២- កាលបរិច្ឆេទ ពេលវេលា និង ទីកន្លែង នៃការប្រឡង នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**ប្រការ ១៧ : អនាមិកភាព**

១- អនាមិកភាពនៃបេក្ខជននឹងត្រូវបានគោរព នៅពេលចម្លើយរបស់បេក្ខជនត្រូវបានដាក់ពិន្ទុ។

២- ចម្លើយរបស់បេក្ខជនអាចត្រូវបានបោះពុម្ពផ្សាយ និងប្រើប្រាស់នៅពេលណាមួយ សម្រាប់ការស្រាវជ្រាវ សម្រាប់គោលបំណងស្ថិតិ ឬ ការបណ្តុះបណ្តាល ដោយគោរពអនាមិកភាពរបស់បេក្ខជន។

**ប្រការ ១៨ : លទ្ធផល**

១- ក្រសួងពាណិជ្ជកម្មនឹងរាយនាមនៅក្នុងបញ្ជីឈ្មោះ តាមលំដាប់ព្យញ្ជនៈរបស់បេក្ខជនដែលបានទទួលជោគជ័យក្នុងការប្រឡង។

២- លេខាធិការដ្ឋានប្រឡងទទួលខុសត្រូវក្នុងការចងក្រង ផ្សព្វផ្សាយស្ថិតិ ស្តីពីលទ្ធផលនៃការប្រឡង។ ក្រុមប្រឹក្សា នឹងសម្រេចអំពីព័ត៌មានដែលត្រូវផ្សព្វផ្សាយ។

**ប្រការ ១៩ : ការរក្សាការសម្ងាត់**

អនុលោមទៅតាមប្រការ១៧ សមាជិកក្រុមប្រឹក្សា សមាជិកគណៈកម្មការ និងបុគ្គលិកដែលធ្វើការនៅក្នុងលេខាធិការដ្ឋានប្រឡង ត្រូវរក្សាការសម្ងាត់ទាំងក្នុងអំឡុងពេល និងក្រោយពេលកាន់ការងារ នូវរាល់ព័ត៌មាន ទាំងអស់ និង ការពិភាក្សាណាមួយដែលធ្វើឡើងទាក់ទងនឹងបេក្ខជន។

**ប្រការ ២០ : ការបណ្តុះបណ្តាលត្រៀមប្រឡង**

១- បេក្ខជនដែលអាចចុះឈ្មោះចូលរៀនត្រៀមប្រឡង ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ឬខ្ពស់ជាងនេះ ឬ លិខិតបញ្ជាក់ដែលមានតម្លៃស្មើ ដោយមានបញ្ជាក់ភាពត្រឹមត្រូវ។

២- អ្នកចូលរៀនត្រៀមប្រឡងត្រូវដាក់ពាក្យស្នើសុំ និង បង់ថ្លៃចូលរៀន តាមការកំណត់របស់ក្រុមប្រឹក្សាប្រឡង ដើម្បីសម្រួលដល់ការចំណាយចាំបាច់នានា។

៣- មន្ត្រីរបស់ក្រសួងពាណិជ្ជកម្មត្រូវបានលើកលែងក្នុងការបង់ថ្លៃចូលរៀន។

៤- វគ្គបណ្តុះបណ្តាលត្រៀមប្រឡង ត្រូវប្រើប្រាស់ពេលយ៉ាងតិចហុកសិប (៦០) ម៉ោង។

**ប្រការ ២១ : លក្ខខណ្ឌចុះឈ្មោះប្រឡង**

១- បេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡង ត្រូវបញ្ចប់វគ្គបណ្តុះបណ្តាលត្រៀម មុនកាលបរិច្ឆេទប្រឡង ដែលបានរៀបចំឡើងនៅចន្លោះពេលទៀងទាត់មួយ ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។

២- មន្ត្រីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលបានចូលបម្រើការងារយ៉ាងតិច ៥ ឆ្នាំ ត្រូវបានលើកលែងក្នុងការចូលរៀនវគ្គត្រៀមប្រឡង។

៣- បេក្ខជនទាំងឡាយដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ជំនាញកម្មសិទ្ធិបញ្ញា ឬខ្ពស់ជាង ដែលទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច និងមានបទពិសោធន៍ក្នុងការងារកម្មសិទ្ធិបញ្ញា ចំនួន ៥ ឆ្នាំយ៉ាងតិច

នៅក្នុងភ្នាក់ងារកម្មសិទ្ធិបញ្ញា ឬ ក្រុមហ៊ុនច្បាប់ ឬ ក្នុងការិយាល័យដែលទទួលបន្ទុកកម្មសិទ្ធិបញ្ញា នៃក្រុមហ៊ុនណាមួយ ត្រូវបានលើកលែងក្នុងការចូលរៀនវគ្គត្រៀមប្រឡង។

៤- បេក្ខជនត្រូវជាវពាក្យស្នើសុំចុះឈ្មោះប្រឡង។ ក្រុមប្រឹក្សាប្រឡងជាអ្នកកំណត់តម្លៃពាក្យស្នើសុំចុះឈ្មោះប្រឡង ដើម្បីមានថវិកាទ្រទ្រង់ការចំណាយចាំបាច់នានាក្នុងដំណើរការប្រឡង។

៥- មន្ត្រីនៃក្រុមប្រឹក្សាប្រឡង គណៈកម្មការប្រឡង និង លេខាធិការដ្ឋាន ដែលកំពុងកាន់មុខតំណែង មិនមានសិទ្ធិចុះឈ្មោះប្រឡងទេ។ មន្ត្រីទាំងនោះនឹងមានសិទ្ធិចុះឈ្មោះប្រឡង បន្ទាប់ពីតំណែងរបស់ខ្លួនត្រូវបានបញ្ចប់។

## ប្រការ ២២ : កម្មវិធីសិក្សា និងការប្រឡង

កម្មវិធីសិក្សា និង ការប្រឡងសំដៅផ្តល់ ដល់បេក្ខជននូវចំណេះដឹងជ្រៅជ្រះពី ÷

១- សញ្ញាណជាមូលដ្ឋាននៃកម្មសិទ្ធិបញ្ញា

២- ច្បាប់កម្មសិទ្ធិបញ្ញាកម្ពុជា ដែលរួមមាន : ច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និង ច្បាប់ និង បទប្បញ្ញត្តិនានា ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ របស់ព្រះរាជាណាចក្រកម្ពុជា។

៣- ច្បាប់កម្ពុជាដទៃទៀតដែលត្រូវបានចាត់ទុកដោយក្រុមប្រឹក្សាថា មានសារៈសំខាន់ចំពោះការអនុវត្តន៍របស់ភ្នាក់ងារតំណាងស្របច្បាប់។

៤- កិច្ចព្រមព្រៀង អនុសញ្ញា សន្ធិសញ្ញាអន្តរជាតិ ដែលត្រូវបានចាត់ទុកដោយក្រុមប្រឹក្សាថា មានសារៈសំខាន់ចំពោះការអនុវត្តន៍ការងាររបស់ភ្នាក់ងារតំណាងស្របច្បាប់។

៥- ការអនុវត្តន៍ជាក់ស្តែងក្នុងការចុះបញ្ជី ការប្តឹងជំទាស់ និងដោះស្រាយវិវាទ កម្មសិទ្ធិបញ្ញា។

## ប្រការ ២៣ : វិញ្ញាសារប្រឡង

១- ការប្រឡងមានវិញ្ញាសារសរសេរ និង ឬ ផ្ទាល់មាត់។

២- ក្រុមប្រឹក្សានឹងសម្រេចអំពីវិញ្ញាសា និងរយៈពេលប្រឡង។ វិញ្ញាសាប្រឡងនឹងរៀបចំចេញពីកម្មវិធីសិក្សាដូចក្នុងប្រការ ២២។

## ប្រការ ២៤ : ការដាក់ពិន្ទុ

ក្រុមប្រឹក្សាត្រូវផ្តល់ការណែនាំដែលចាំបាច់ដល់គណៈកម្មការប្រឡង ដើម្បីធានាឱ្យប្រាកដថា ចម្លើយរបស់បេក្ខជនត្រូវបានដាក់ពិន្ទុតាមរបៀបតែមួយ។

## ប្រការ ២៥ : ការប្រឡងជាប់ជាស្ថាពរ

បេក្ខជន ដែលប្រឡងជាប់ជាស្ថាពរ នឹងត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម។

## ប្រការ ២៦ : ករណីលើកលែងក្នុងការប្រឡង

អ្នកត្រួតពិនិត្យខ្លឹមសារម៉ាកលម្អិត ដែលមានបទពិសោធន៍ក្នុងការងារយ៉ាងតិចចំនួន ០៦ ឆ្នាំ និង មន្ត្រីជំនាញច្បាប់កម្មសិទ្ធិបញ្ញាដែលធ្លាប់បង្រៀនជំនាញកម្មសិទ្ធិបញ្ញាដល់បេក្ខជនត្រៀមប្រឡង ដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម នឹងត្រូវចាត់ទុកថា មានគុណសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ដោយមិនបាច់ចូលរួមក្នុងការប្រឡង និងត្រូវបានចាត់ទុកថាប្រឡងជាប់ជាស្ថាពរ ។

## ប្រការ ២៧ : រយៈពេលនៃការទទួលស្គាល់

ការទទួលស្គាល់ភ្នាក់ងារតំណាងស្របច្បាប់ជារូបវន្តបុគ្គល មិនមានរយៈពេលកំណត់ឡើយ ។ ចំពោះនីតិបុគ្គល រយៈពេលនៃការទទួលស្គាល់នេះក៏គ្មានរយៈពេលកំណត់ដែរ ដរាបណានីតិបុគ្គលនោះ នៅតែមានរូបវន្តបុគ្គលជាភ្នាក់ងារតំណាង ឈរឈ្មោះអោយ ។

## ប្រការ ២៨ : ភ្នាក់ងារស្របច្បាប់នៃម្ចាស់ម៉ាកដែលមានស្រាប់

ដើម្បីធានាគុណភាពភ្នាក់ងារស្របច្បាប់នៃម្ចាស់ម៉ាក នីតិបុគ្គលទាំងឡាយណាដែលបានទទួលស្គាល់ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មកម្មសិទ្ធិបញ្ញា (Intellectual Property Automation System-IPAS) រួចហើយមុនប្រកាសនេះចូលជាធរមាន ត្រូវជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់ដែលជារូបវន្តបុគ្គលដើម្បីឈរឈ្មោះអោយក្នុងរយៈពេល ៥ ឆ្នាំ បន្ទាប់ពីប្រកាសនេះចូលជាធរមាន ពុំនោះសោតទេ នីតិបុគ្គលទាំងឡាយនោះ នឹងបាត់បង់សិទ្ធិជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ។

## ប្រការ ២៩ : មោឃភាពនៃការទទួលស្គាល់

មោឃភាពនៃការទទួលស្គាល់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ត្រូវបានកំណត់ដូចខាងក្រោម ÷

១- ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក សុំបញ្ចប់ការទទួលស្គាល់ដោយខ្លួនឯង ។

២- ទទួលបានការទទួលស្គាល់ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ដោយមធ្យោបាយក្លែងបន្លំណាមួយ ។

៣- លែងមាននិវេសនដ្ឋាន និងទីតាំងប្រកបអាជីវកម្ម ឬការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤- ប្រព្រឹត្តផ្ទុយនឹងច្បាប់ និង បទប្បញ្ញត្តិ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងម៉ាកទំនិញសម្គាល់ភូមិសាស្ត្រ ។

៥- ធ្វើឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់អ្នកដាក់ពាក្យសុំចុះបញ្ជីម៉ាក ឬអ្នកដែលមានសិទ្ធិលើម៉ាក ។

៦- មិនបានបង់ប្រាក់កម្រៃសមាជិកភាពប្រចាំឆ្នាំ ។

៧- ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក បាត់បង់សមត្ថភាព ឬ ទទួលមរណភាព ។

៨- ចំពោះនីតិបុគ្គល លែងមានរូបវន្តបុគ្គលជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឈរឈ្មោះអោយ ។

**ប្រការ ៣០ : កម្រៃសម្រាប់ការចុះបញ្ជីទទួលស្គាល់ភ្នាក់ងារតំណាង**

ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកដែលទទួលស្គាល់ជាផ្លូវការ និងជារូបវន្តបុគ្គល ត្រូវបង់កម្រៃសមាជិកភាពរបស់ខ្លួនប្រចាំឆ្នាំ តាមប្រកាសអន្តរក្រសួង ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៣១ :**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣២ :**

នាយិកាខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានគ្រប់អង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចំលងជូន:**

-ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**

-ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-សាលាខេត្ត រាជធានី

-ដូចប្រការ ៣២

-រាជកិច្ច ✓

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
**លេខ ........ ពណ.ចបព**

**ភ្នំពេញថ្ងៃទី ........ ខែ ........ ឆ្នាំ ២០១០**

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ភីង ផែរ៉ាដាយ**
PINK PARADISE Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០៧៧៣KH/២០១០ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ហេង សុខា**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិវត្តដំណាក់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។

៥- កម្មវត្ថុអាជីវកម្ម : -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន ម៉ាស្សា ទីភ្នាក់ងារទេសចរណ៍ ដឹកជញ្ជូនភ្ញៀវទេសចររមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទនីប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

ភឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងព័ត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តសៀមរាប
- មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ...... ពណ.ចបព

ភ្នំពេញថ្ងៃទី ...... ខែ ...... ឆ្នាំ ២០ ......

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ជំរាបមក

លោក HUYNH BINH MINH ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **អ៊ែរ ផែកឃិច ស៊ើវីស**
អាសយដ្ឋាន : លេខ ១១៣ មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កម្មវត្ថុ :** ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **អ៊ែរ ផែកឃិច ស៊ើវីស** **AIR PACKAGE SERVICE Co., Ltd.**

**យោង :**
- សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី 09/ 04 / 2010
- កំណត់ហេតុនៃអង្គប្រជុំវិសាមញ្ញនិងសេចក្ដីសំរេចសមូហភាព ថ្ងៃទី 26 / 03 / 2010
- លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងថ្មីរបស់ក្រុមហ៊ុន ចុះហត្ថលេខា ថ្ងៃទី 26 / 03 / 2010
- សេចក្ដីប្រកាសស្ដីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ 413 ចេញផ្សាយថ្ងៃទី 30 - 04 - 2010

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និង តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **អ៊ែរ ផែកឃិច ស៊ើវីស** **AIR PACKAGE SERVICE Co., Ltd.** ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ **Co. 4973/08E** ចុះថ្ងៃទី **06 - 06- 2008** ទៅតាមចំណុចដូចមានក្នុងលិខិតស្នើ និងយោងខាងលើគឺ :

-ការលាលែងចេញសមាជិកហ៊ុនចំនួន ០១ រូប គឺលោក **ង៉ាល់ គន្ធា** " អភិបាលចាស់ "
-ការបញ្ចូលសមាជិកហ៊ុនថ្មី ចំនួន ០១ រូប គឺលោកស្រី VU THI THU ANH
-ការធ្វើអនុប្បទានភាគហ៊ុន
-សមាសភាពសមាជិកភាគហ៊ុនថ្មី :
- លោក HUYNH BINH MINH ( សញ្ជាតិ : វៀតណាម ) កាន់កាប់ភាគហ៊ុនចំនួន ៤៧៥ ភាគហ៊ុន
- លោក PERERA BENTOTABADUGE TERRENCE MARIUS KEVIN ( សញ្ជាតិ: ស្រីលង្កា ) កាន់កាប់ភាគហ៊ុនចំនួន ៣៧៥ ភាគហ៊ុន
- លោកស្រី VU THI THU ANH ( សញ្ជាតិ: វៀតណាម ) កាន់កាប់ភាគហ៊ុនចំនួន ១៥០ ភាគហ៊ុន

- ការតែងតាំងលោកស្រី VU THI THU ANH ជាអភិបាលក្រុមហ៊ុន
-សមាសភាពក្រុមប្រឹក្សាភិបាលថ្មី :
- លោក HUYNH BINH MINH ប្រធានក្រុមប្រឹក្សាភិបាល
- លោក PERERA BENTOTABADUGE TERRENCE MARIUS KEVIN អភិបាល
- លោកស្រី VU THI THU ANH អភិបាល

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ បើប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តតាមការសមស្រប ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថា

**ចម្លងជូន:**

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសុខាភិបាល-ធនាគារជាតិនៃកម្ពុជា
-ក្រសួងទេសចរណ៍ -ក្រសួងពត៌មាន
-ក្រសួងអប់រំយុវជន និងកីឡា-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
-ឯកសារ - កាលប្បវត្តិ

ហ.ត.ហ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ... ពណ.ចបព

ភ្នំពេញថ្ងៃទី ... ខែ ... ឆ្នាំ ២០...

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **រតនៈ អេគ្រីខលឈ័រ អេន ឌីវេឡុបមេន (ខេមបូឌា)**
RATANAK AGRICULTURE AND DEVELOPMENT (CAMBODIA) Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០៧៧៥KH/២០១០ ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ឆេង រតនៈ** ប្រធានក្រុមប្រឹក្សាភិបាល
លោក SORAART TANAMPAI អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៨៩F ផ្លូវលេខ ៦៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ [illegible] ពណ.ចបព

ភ្នំពេញថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០[illegible]

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **នគរមាស ត្រេឌីង**
NOKORMEAS TRADING Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០៧៧៦KH/២០១០ ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១០
មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **នេង រិទ្ធិ** ប្រធានក្រុមប្រឹក្សាភិបាល
លោក **ឃុន ផល្លី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៥៤ ផ្លូវលេខ ២៧១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-មជ្ឈមណ្ឌលពាណិជ្ជកម្ម ផ្សារទំនើប
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

សសរ - ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
**លេខ** ១៩៣៧ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ២២ **ខែ**មេសា **ឆ្នាំ** ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ជំរាបមក

លោកឧកញ៉ា **ខូច ផល្លាបុត្រ** ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **សេដ្ឋីកុលា**

អាសយដ្ឋាន : លេខ ៧៦ ផ្លូវលេខ ៥៩២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**កម្មវត្ថុ** : ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **សេដ្ឋីកុលា** SETHIKULA Co., Ltd.

**យោង** : - សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី 24 / 03 / 2010

- កំណត់ហេតុនៃអង្គប្រជុំនិងសេចក្តីសំរេចសមូហភាព ចុះថ្ងៃទី 11 / 03 / 2010
- លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងថ្មីរបស់ក្រុមហ៊ុន ចុះហត្ថលេខា ថ្ងៃទី 11 / 03 / 2010
- សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ 412 ចេញផ្សាយថ្ងៃទី 15 - 04 - 2010

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកឧកញ៉ាថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **សេដ្ឋីកុលា** SETHIKULA Co., Ltd. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 10275/07P ចុះថ្ងៃទី 03 - 07 - 2007 ទៅតាមចំណុចដូចមានក្នុងលិខិតស្នើ និងយោងខាងលើគឺ :

-ការប្តូរទីស្នាក់ការក្រុមហ៊ុន :

-ទីស្នាក់ការចាស់ : លេខ ២៤ ផ្លូវលេខ ២៤០ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្តូរមកទីស្នាក់ការថ្មី : លេខ ៧៦ ផ្លូវលេខ ៥៩២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-ការលាលែងចេញសមាជិកហ៊ុន ចំនួន ០១ រូប គឺលោកឧកញ៉ា **ខូច ផល្លាបុត្រ**

-ការបញ្ចូលសមាជិកហ៊ុនថ្មី ចំនួន ០១ ជានីតិបុគ្គល គឺក្រុមហ៊ុន **សុកហ៊្វីន ខេស៊ីឌី** តំណាងដោយ លោកឧកញ៉ា **ខូច ផល្លាបុត្រ**

-ការធ្វើអនុប្បទានភាគហ៊ុន

-សមាសភាពសមាជិកភាគហ៊ុនថ្មី :

- ក្រុមហ៊ុន **សុកហ៊្វីន ខេស៊ីឌី** កាន់កាប់ភាគហ៊ុនចំនួន ១.000 ភាគហ៊ុន

-សមាសភាពក្រុមប្រឹក្សាភិបាលថ្មី :

- លោកឧកញ៉ា **ខូច ផល្លាបុត្រ** "តតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
- លោក PHILIPPE MICHEL CAMILLE MONNIN "តតិយជន" អភិបាល

-ការកែប្រែកម្មវត្ថុអាជីវកម្ម :

. កម្មវត្ថុអាជីវកម្មចាស់ :

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណកម្មទំនិញគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

. កម្មវត្ថុអាជីវកម្មថ្មី :

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ និងចិញ្ចឹមសត្វ និង

-សកម្មភាពពាណិជ្ជកម្ម និងឧស្សាហកម្មដែលទាក់ទងនឹងសកម្មភាពដូចមានចែងខាងលើ ។

-ការប្តូរសញ្ជាតិក្រុមហ៊ុន :

ពីសញ្ជាតិ : ខ្មែរ

មកសញ្ជាតិ : បរទេស

និងប្តូរអត្តលេខចុះបញ្ជីពាណិជ្ជកម្មពីលេខ Co. 10275/07P ចុះថ្ងៃទី 03 - 07- 2007 ទៅលេខ Co. 10275E/2007 ចុះថ្ងៃទី 24 - 03- 2010 ឯវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ៣៦៦៣ ពណ.នគក ចុះថ្ងៃទី ១៣- ០៩ - ២០០៧ របស់ក្រសួងពាណិជ្ជកម្មត្រូវចាត់ទុកជានិរាករណ៍ ។

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ បើប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកឧកញ៉ាជ្រាប និងអនុវត្តតាមការសមស្រប ។/.

**ជ. ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចំលងជូន:**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងបរិស្ថាន
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ - កាលប្បវត្តិ

លជ

**ក៏ម ស៊ីថន**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
**លេខ ១៩៣៧ ពណ.ចបព**

**ភ្នំពេញថ្ងៃទី** [illegible] **ខែ**មេសា **ឆ្នាំ ២០១០**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**ជំរាបមក**

លោក PARK HUNG SEOG ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **ឌាមីយុង (ខេមបូឌា)**
អាសយដ្ឋាន : អគារ IOC F4 , R8 លេខ ២៥៤ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**កម្មវត្ថុ** : ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ឌាមីយុង (ខេមបូឌា)** DAEMYUNG ( CAMBODIA ) Co., Ltd.

**យោង** : - សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី 07 / 04 / 2010
- កំណត់ហេតុនៃអង្គប្រជុំនិងសេចក្តីសំរេចសមូហភាព ចុះថ្ងៃទី 09 / 03 / 2010
- លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងថ្មីរបស់ក្រុមហ៊ុន ចុះហត្ថលេខា ថ្ងៃទី 09 / 03 / 2010
- សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ 413 ចេញផ្សាយថ្ងៃទី 30 - 04 - 2010

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ឌាមីយុង (ខេមបូឌា)** DAEMYUNG ( CAMBODIA ) Co., Ltd. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 10151/ 07P ចុះថ្ងៃទី 12 - 06 - 2007 ទៅតាមចំណុចដូចមានក្នុងលិខិតស្នើ និងយោងខាងលើគឺ :

-ការប្តូរទីស្នាក់ការក្រុមហ៊ុន :
-ទីស្នាក់ការចាស់ : ដីឡូត៍លេខ ៥១-៥៣ ល្វែងលេខ ៣០១ ផ្លូវលេខ ៣៥៧ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។
ប្តូរមកទីស្នាក់ការថ្មី : អគារ IOC F4 , R8 លេខ ២៥៤ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

-ការលាលែងចេញសមាជិកហ៊ុន ចំនួន ០២ រូប គឺលោក **លី សាំងហ្គាប់** " ប្រធានក្រុមប្រឹក្សាភិបាលចាស់ " និងលោកស្រី PARK CHUNG HEE

-ការបញ្ចូលសមាជិកហ៊ុនថ្មី ចំនួន ០២ ជានីតិបុគ្គល គឺ :
.ក្រុមហ៊ុន DAEMYUNG LEISURE INDUSTRY CO., LTD. តំណាងដោយលោក PARK HUNG SEOG
.ក្រុមហ៊ុន **ទ្រី ត្រាស់ ខូ អិលធីឌី** តំណាងដោយលោក **លី សាំងហ្គាប់**

-ការផ្ទេរអនុប្បទានភាគហ៊ុន

-សមាសភាពសមាជិកភាគហ៊ុនថ្មី :
- ក្រុមហ៊ុន **ទ្រី ត្រាស់ ខូ អិលធីឌី** កាន់កាប់ភាគហ៊ុនចំនួន ៥១០ ភាគហ៊ុន
- ក្រុមហ៊ុន DAEMYUNG LEISURE INDUSTRY CO., LTD. កាន់កាប់ភាគហ៊ុនចំនួន ៤៩០ ភាគហ៊ុន ។ ...

-សមាសភាពក្រុមប្រឹក្សាភិបាលថ្មី :

- លោក PARK HUNG SEOG " គតិយជន " ប្រធានក្រុមប្រឹក្សាភិបាល
- លោកស្រី PARK CHUNG HEE " គតិយជន " អភិបាល

និងប្តូរអត្តលេខចុះបញ្ជីពាណិជ្ជកម្មពីលេខ Co. 10151/ 07P ចុះថ្ងៃទី 12 - 06 - 2007 ទៅលេខ Co. 10151KH/2007 ចុះថ្ងៃទី 12 - 06 - 2007 ដដែលមានវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ២២២៥ ពណ.ទតក ចុះថ្ងៃទី ១៤- ០៦ - ២០០៧ របស់ក្រសួងពាណិជ្ជកម្មត្រូវចាត់ទុកជានិរាករណ៍ ។

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ បើប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តតាមការសមស្រប ។ថេត

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

កើម គុណវិច

**ចម្លងជូន:**

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសុខាភិបាល
-ធនាគារជាតិនៃកម្ពុជា
-ក្រសួងទេសចរណ៍
-ក្រសួងពត៌មាន - ក្រសួងបរិស្ថាន
-ក្រសួងអប់រំយុវជន និងកីឡា
-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ ✓
-សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
-ឯកសារ - កាលប្បវត្តិ

សរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ [illegible] ពណ.ចបព

ភ្នំពេញថ្ងៃទី [illegible] ខែមេសា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហេង សេន មេថល អ៊ិមផត អិចផត (ខេមបូឌា)**
**HENG SEN METALS IMPORT EXPORT (CAMBODIA) Co., Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០៧៩៣E/២០១០ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក YE JIAN

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : វីឡាភ្លោះលេខ ៤៩ ផ្លូវលេខ ៣ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកាំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន ទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា និងត្រា

ចាម ប្រសិទ្ធ

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ [illegible] ពណ.ចបព

ភ្នំពេញថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អូរៀនថល ម៉ាញនីង អ៊ិនវេសមេន**
ORIENTAL MINING INVESTMENT Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០៧៧៨E/២០១០ ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកស្រី ZHAO WEN

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៩៧ E2 ផ្លូវលេខ ៣៥0 សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្ដូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
.. នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្ដូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះ និងព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ដ វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ដ
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ក ស ទ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៤០ ពណ.ចបព

ភ្នំពេញ ថ្ងៃទី ១៣ ខែ [illegible] ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

| | | |
|---|---|---|
| ១- នាមករណ៍របស់ក្រុមហ៊ុន | : | **ខេមបូ អិចស៊ីម រ៉ាយស៍**<br>**CAMBO EXIM RICE Co., Ltd.** |
| អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : | Co. ០៨២៤KH/២០១០ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១០ |
| មានទ្រង់ទ្រាយជា | : | សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត |
| ២- អភិបាលក្រុមហ៊ុន | : | លោកស្រី **ជីវ កេវ៉ាលី** |
| ៣- ដើមទុនក្រុមហ៊ុន | : | ចំនួន ២០.០០០.០០០ រៀល |
| ៤- ទីស្នាក់ការក្រុមហ៊ុន | : | លេខ ៧៥៣ Eo មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។ |
| ៥- កម្មវត្ថុអាជីវកម្ម | : | -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ<br>-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ<br>-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង<br>-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ<br>-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ<br>-បើកសាលារៀន<br>-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម<br>-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម<br>-សេវាផ្សាយពាណិជ្ជកម្ម<br>-បោះពុម្ពផ្សាយ<br>-ផលិតខ្សែភាពយន្ត វីដេអូ CD<br>-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ<br>-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន<br>-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់<br>-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត<br>-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ<br>-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។ |

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុរដ្ឋលេខាធិការ**

**ម៉ូ សារ៉ាន់**

**<u>ចម្លងជូន</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

សស: - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៥៤៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៣ ខែ ០៤ ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ប្លែក ឡែន រ៉ាប់ប៊ើរ ទ្រី (ខេមបូឌា)**
**BLACK LAND RUBBER TREE (CAMBODIA) Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ០៧៩២E/២០១០ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១០

មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក YE CHAOQUN

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : វីឡាភ្លោះលេខ ៤៩ ផ្លូវលេខ ៣ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ - ពិសេសដាំដំណាំកៅស៊ូ
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការដូលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដូសដុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ